ព្រឹត្តិបត្រព័ត៌មានអំពីផ្នែកស្តារលទ្ធភាពពលកម្ម

ផ្នែកការស្តារលទ្ធភាពពលកម្ម ACCESS 2

កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២

ការពង្រឹងសេវាស្តារលទ្ធភាពពលកម្មនៅកម្ពុជា

កម្មវិធី ACCESS 2 កំពុងពង្រឹងប្រព័ន្ធស្តារលទ្ធភាពពលកម្មនៅកម្ពុជា ដើម្បីឱ្យប្រជាពលរដ្ឋកាន់តែច្រើនអាចទទួលបានសេវាស្តារលទ្ធភាពពលកម្ម និងបច្ចេកវិទ្យានៃគ្រឿងជំនួយប្រកបដោយគុណភាពនៅជិតកន្លែងរស់នៅរបស់ពួកគាត់។ តាមរយៈកិច្ចសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូឯកទេស កម្មវិធីនេះគាំទ្រដល់ការតាក់តែងគោលនយោបាយ ការពង្រឹងធនធានពង្រីកការផ្តល់សេវា និងការសម្របសម្រួលការបញ្ជូន។ ការវិនិយោគទាំងនេះ កំពុងរួមចំណែកដល់ប្រព័ន្ធស្តារលទ្ធភាពពលកម្មប្រកបដោយការសម្របសម្រួល ងាយស្រួលទទួលបាន និងមាននិរន្តរភាពកាន់តែប្រសើរសម្រាប់ជនមានពិការភាព និងប្រជាពលរដ្ឋដែលត្រូវការសេវាស្តារលទ្ធភាពពលកម្ម។

ចំណុចសង្ខេបអំពីផ្នែកការស្តារលទ្ធភាពពលកម្ម

- ប្រជាពលរដ្ឋ ៣១.៤៧៥នាក់ ទទួលបានសេវា និងឧបករណ៍ជំនួយ
- បានផ្តល់ឧបករណ៍ជំនួយ ចំនួន ១៤.០៩៥ គ្រឿង
- បានផ្តល់ការព្យាបាលដោយ ចលនា ៨៧.៩៧១ដង
- បានបង្កើតផ្នែកស្តារលទ្ធភាពពលកម្ម តាមមន្ទីរពេទ្យចំនួន ៩
- បានផ្តល់ការគាំទ្រដល់ មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា ចំនួន ៣
- បានផ្តល់វគ្គបណ្តុះបណ្តាលដល់អ្នកផ្តល់សេវាថែទាំសុខភាពចំនួន ១៤០ នាក់
- បានផ្តល់អាហារូបករណ៍ចំនួន ២១ សម្រាប់ការបណ្តុះបណ្តាលឯកទេសស្តីពីការស្តារលទ្ធភាពពលកម្ម
- បានដាក់បញ្ចូលការស្តារលទ្ធភាពពលកម្មទៅក្នុងគោលនយោយ យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំថ្នាក់ជាតិ ចំនួន ៧

តើកម្មវិធី ACCESS 2 អនុវត្តសកម្មភាពអ្វីខ្លះ?

១ ពង្រឹងប្រព័ន្ធស្តារលទ្ធភាពពលកម្ម

គាំទ្រដល់គោលនយោបាយ យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំថ្នាក់ជាតិ ដែលទទួលស្គាល់ការស្តារលទ្ធភាពពលកម្មថាជាផ្នែកមួយដ៏សំខាន់នៃប្រព័ន្ធសុខាភិបាល និងការរៀបចំផែនការធនធានមនុស្ស។

២ ពង្រីកសេវាស្តារលទ្ធភាពពលកម្ម

គាំទ្រដល់កន្លែងផ្តល់សេវាស្តារលទ្ធភាពពលកម្ម ឧបករណ៍ជំនួយ និងផ្នែកឯកទេសនានា ដើម្បីបង្កើនការបង្ហិតសេវាឱ្យនៅក្បែរសហគមន៍។

៣ កសាងធនធានជំនាញ

វិនិយោគលើការបណ្តុះបណ្តាលវិជ្ជាជីវៈ អាហារូបករណ៍ និងការយល់ដឹងអំពីអាជីព ដើម្បីពង្រឹងធនធានផ្នែកស្តារលទ្ធភាពពលកម្មនៅកម្ពុជា។

៤ ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធបញ្ជូនបន្ត

ពង្រឹងការសម្របសម្រួលរវាងមន្ទីរពេទ្យ មណ្ឌលសុខភាព ផ្នែកស្តារលទ្ធភាពពលកម្ម និងមជ្ឈមណ្ឌលស្តារលទ្ធភាព



សកម្មភាពលេចធ្លោរបស់ផ្នែកស្តារលទ្ធភាពពលកម្ម

កិច្ចប្រជុំក្រុមការងារស្តារលទ្ធភាពពលកម្ម

កិច្ចប្រជុំក្រុមការងារផ្នែកស្តារលទ្ធភាពពលកម្មប្រចាំឆមាស ប្រមូលផ្តុំដៃគូរដ្ឋាភិបាល ដៃគូអនុវត្តជាយុទ្ធសាស្ត្រផ្នែកស្តារលទ្ធភាពពលកម្ម និងភាគីពាក់ព័ន្ធ ដើម្បីពិនិត្យមើលវឌ្ឍនភាព ចែករំលែកមេរៀនដែលរៀនសូត្របាន និងកំណត់អាទិភាពសម្រាប់ការពង្រឹងសេវាស្តារលទ្ធភាពពលកម្ម។ កិច្ចពិភាក្សាផ្តោតលើការពង្រឹងគុណភាព សមត្ថភាពធនធានមនុស្ស ជាសុកវត្ថុ និងនិរន្តរភាព ដើម្បីធ្វើឱ្យប្រសើរឡើងនូវការទទួលបានសេវាស្តារលទ្ធភាពពលកម្មប្រកបដោយសមធម៌សម្រាប់ប្រជាពលរដ្ឋនៅទូទាំងប្រទេសកម្ពុជា។

ផ្នែកស្តារលទ្ធភាពពលកម្ម

ដៃគូ សកម្មភាព និងលទ្ធផល

តើយើងធ្វើការជាមួយអ្នកណាខ្លះ?

ភាពដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា

- ក្រសួងសុខាភិបាល
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- មូលនិធិជនពិការ
- មន្ទីរសុខាភិបាលខេត្ត
- មន្ទីរពេទ្យថ្នាក់ជាតិ និងខេត្ត
- មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា

ដៃគូអនុវត្តជាយុទ្ធសាស្ត្រ

- អង្គការសុខភាពពិភពលោក (WHO)
- អង្គការ Exceed Worldwide (Exceed)
- អង្គការ Handicap International (HI)
- អង្គការ OIC Cambodia
- គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម (ICRC)

សកម្មភាពចម្បងៗ

១ គោលនយោបាយ និងប្រព័ន្ធរឹងមាំជាងមុន

ការស្តារលទ្ធភាពពលកម្មត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំថ្នាក់ជាតិចំនួន៧ ដែលពង្រឹងការទទួលស្គាល់របស់ខ្លួននៅក្នុងប្រព័ន្ធសុខាភិបាល។

២ សេវាមានការសម្របសម្រួលកាន់តែប្រសើរ

ប្រព័ន្ធបញ្ជូនបន្ត បានភ្ជាប់មណ្ឌលសុខភាព មន្ទីរពេទ្យ ផ្នែកស្តារលទ្ធភាពពលកម្មតាមមន្ទីរពេទ្យ និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា។

៣ ការកសាងធនធានកម្ពុជា

អ្នកផ្តល់សេវាថែទាំសុខភាពចំនួន១៤០នាក់ បានទទួលវគ្គបណ្តុះបណ្តាល និងអាហារូបករណ៍ចំនួន២១ ត្រូវបានផ្តល់ជូន ព្រមទាំងបានផ្សព្វផ្សាយដល់សិស្សវិទ្យាល័យចំនួន១.១២៥នាក់ ស្តីពីជំនាញផ្នែកការព្យាបាលដោយចលនា។

៤ ការពង្រីកលទ្ធភាពទទួលបានសេវា

បានបង្កើតផ្នែកស្តារលទ្ធភាពពលកម្មតាមមន្ទីរពេទ្យចំនួន៩ បានផ្តល់ការគាំទ្រដល់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាចំនួន៣ និងបានផ្តល់សេវាដល់ប្រជាពលរដ្ឋចំនួន ៣១.៤៧៥នាក់។

សកម្មភាពអំពីផ្នែកស្តារលទ្ធភាពពលកម្ម







អគារ ANINA ជាន់ទី ៣ ផ្លូវ ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

info@access2cambodia.org www.access2cambodia.org

ACCESS 2 ត្រូវបានគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងគ្រប់គ្រងដោយ Abt Global។